政府統計

# ការធ្វើជំរឿន ឆ្នាំ២០២០
# របៀបបំពេញក្រដាសជំរឿន

ក្រសួងសាធារណៈការ
នាយកដ្ឋានស្ថិតិ

យើងមានឯកសារពន្យល់អំពីគោលបំណងនៃការធ្វើជំរឿនប្រជាជន និងរបៀបបំពេញលើក្រដាសជំរឿន សូមយក”ឯកសារបកប្រែនៃក្រដាសជំរឿន”និង”របៀបបំពេញក្រដាសជំរឿន”នេះ ចាប់ពីទំព័រទី2~8ធ្វើជាឯកសារជំនួយ ហើយសូមបំពេញលើក្រដាសជំរឿនដែលមានជាភាសាជប៉ុន។ ខ្លឹមសារនៃចំលើយនឹងត្រូវបានយកទៅប្រើប្រាស់សម្រាប់តែធ្វើស្ថិតិប៉ុណ្ណោះ គឺមិនយកទៅប្រើក្នុងគោលបំណងសម្រាប់គ្រប់គ្រងអន្តោប្រវេសន៍ឬសម្រាប់ការស៊ើបអង្កេតរបស់ប៉ូលីសជាដើមឡើយ។

➢ **調査員の方は，世帯の人から『外国語連絡票』の H で示された調査票の提出方法と回収日時の同じ部分にチェック（☑）を付けてから，この『調査票の記入のしかたの対訳』を世帯の人に渡してください。**

## អំពីវិធីប្រគល់ក្រដាសជំរឿន និង កាលបរិច្ឆេទប្រមូល

□ ប្រគល់ទៅកាន់បុគ្គលិកធ្វើជំរឿន（調査員に提出）… 世帯が『外国語連絡票』の H で 6 を示した場合

យើងខ្ញុំនឹងមកប្រមូលក្រដាសជំរឿនដែលលោកអ្នកបានបំពេញរួចនៅកាលបរិច្ឆេទខាងក្រោម

□ថ្ងៃទី1តុលា (ព្រហស្បតិ៍)　□ថ្ងៃទី2 (សុក្រ)　□ថ្ងៃទី3 (សៅរ៍)　□ថ្ងៃទី4 (អាទិត្យ)　□ថ្ងៃទី5 (ចន្ទ័)　□ថ្ងៃទី6 (អង្គារ)　□ថ្ងៃទី7 (ពុធ)

□ព្រឹកម៉ោង 8～10　□ម៉ោង10～12　□ល្ងាចម៉ោង 0～2　□ម៉ោង 2～4　□ម៉ោង 4～6　□ម៉ោង 6～8

□ ការប្រគល់ដោយផ្ញើរតាមប៉ុស្តិ៍（郵送で提出）… 世帯が『外国語連絡票』の H で 7 を示した場合

សូមបត់ក្រដាសជំរឿនជាបី ហើយដាក់ក្នុងស្រោមសំបុត្រផ្ញើទៅកាន់ប៉ុស្តិ៍ប្រៃសនីយ៍ដែលនៅជិតអ្នកបំផុត ត្រឹមថ្ងៃ៧(ពុធ) ខែតុលា ដោយមិនចាំបាច់បិទតែមទេ។

ប្រសិនបើដល់ថ្ងៃកំណត់ហើយនៅមិនទាន់បានប្រគល់ក្រដាសជំរឿន នៅថ្ងៃបន្ទាប់បុគ្គលិកយើងខ្ញុំនឹងចុះទៅប្រមូលដល់គេហដ្ឋានផ្ទាល់។

## អំពីការធ្វើជំរឿនប្រជាជន

នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២០នេះ យើងនឹងអនុវត្តការធ្វើជំរឿនប្រជាជននៅទូទាំងប្រទេស។

ការធ្វើជំរឿនប្រជាជនគឺអនុវត្តឡើងដោយផ្អែកទៅតាមច្បាប់ស្ថិតិ នេះគឺជាការស្រាវជ្រាវស្ថិតិដ៏សំខាន់ដែលរដ្ឋាភិបាលចាំបាច់ត្រូវអនុវត្ត។ ការធ្វើជំរឿននេះនឹងអនុវត្តលើប្រជាជនទាំងអស់ដែលរស់នៅក្នុងប្រទេសជប៉ុន ដោយមិនគិតអំពីសញ្ជាតិឡើយ។

យោងទៅតាមច្បាប់ស្ថិតិ ប្រជាជនគ្រប់រូបមានកាតព្វកិច្ចបំពេញក្រដាសជំរឿន ហើយប្រគល់អោយមន្ត្រីមូលដ្ឋាន។

ម្យ៉ាងទៀត បុគ្គលិកជំរឿនគ្រប់រូបមានកាតព្វកិច្ចរក្សាការសំងាត់ជាចាំបាច់។

ក្រដាសជំរឿនដែលបានបំពេញរួច យើងនឹងគ្រប់គ្រងអោយបានតឹងរឹង ដោយមិនអោយព័ត៌មានខាងក្នុងនោះលេចចេញក្រៅទេ។ បន្ទាប់ពីការបូកសរុបស្ថិតិបានបញ្ចប់ យើងនឹងកម្ទេចចោលក្រដាសជំរឿនទាំងនោះ។

លទ្ធផលនៃការធ្វើជំរឿនប្រជាជននេះ ក៏នឹងត្រូវបានយកមកប្រើប្រាស់ជាឯកសារមូលដ្ឋានក្នុងការកំណត់វិធានការកសាងទីក្រុងដែលបង្កលក្ខណ:ងាយស្រួលក្នុងការរស់នៅសំរាប់ប្រជាពលរដ្ឋគ្រប់រូប ក៏ដូចជាសំរាប់ជនបរទេសផងដែរ។

A

## ក្រដាសជំរឿន នឹងត្រូវបំពេញដោយគ្រួសារនិមួយៗ

◆ មានសមាជិករស់នៅជាមួយគ្នាដោយប្រកបរបរចិញ្ចឹមជីវិតដូចគ្រួសារទូទៅ ត្រូវបានចាត់ទុកថាជាគ្រួសារមួយ។
◆ បុគ្គលដែលរស់នៅម្នាក់ឯងក្នុងលក្ខណៈជាគ្រួសារមួយ ក៏ត្រូវបានចាត់ទុកជាគ្រួសារមួយផងដែរ។

● ខាងក្រោមនេះ គឺជាការបង្ហាញអំពីការកំណត់ប្រភេទគ្រួសារនិមួយៗ

○ អ្នកដែលរស់នៅផ្ទះជួល

(រួមទាំងការស្នាក់នៅបន្ទប់រួម) ...... អ្នកនៅលីវ ការរស់នៅតែម្នាក់ឯង ក៏អាចរាប់ថាជាគ្រួសារមួយដែរ។
ករណីមានបងប្អូនរស់នៅជាមួយគ្នា រាល់គ្រួសារនិមួយៗនឹងរាប់ថាជាមួយគ្រួសារ។

○ អ្នកធ្វើការនិយោជិតនៅលីវដែលរស់នៅជាមួយគេ...... ករណីដែលរស់នៅផ្ទះជាមួយនិយោជក គឺរាប់បញ្ចូលជាសមាជិកគ្រួសាររបស់និយោជក។
ករណីដែលរស់នៅផ្ទះដោយឡែកពីនិយោជក គឺមិនអាចរាប់បញ្ចូលជាសមាជិករបស់និយោជកបានទេ។ ការរស់នៅម្នាក់ឯងក៏អាចរាប់ថាជាគ្រួសារមួយដែរ។

○ ចំពោះបុគ្គលនៅលីវដែលរស់នៅផ្ទះក្រុមហ៊ុន ឬ អាគារស្ថាប័នរដ្ឋ ...... ការរស់នៅម្នាក់ឯងក៏អាចរាប់ជាគ្រួសារមួយដែរ។

## អំពីការបំពេញលើក្រដាសជំរឿន

● សូមប្រើខ្មៅដៃ ឬ ខ្មៅដៃចុចពណ៌ខ្មៅបំពេញលើក្រដាសជំរឿន។
● សូមគូសនៅលើសញ្ញានេះ「◯」អោយដុតដូចសញ្ញាខាងក្រោយនេះ「⬬」។
● សូមសរសេរតួលេខចាប់ផ្តើមពីផ្នែកខាងស្តាំទៅ ហើយកុំអោយលៀនចេញពីតារាងនិមួយៗ។




## ក្រដាសជំរឿន របៀបបំពេញនៅលើទំព័រទី 1

**អំពីក្រុមគ្រួសារ**

**1 ចំនួនសមាជិកគ្រួសារ**

ករណីសមាជិកគ្រួសារចាប់ពី៥នាក់ឡើងទៅ សូមសរសេរចំនួនសមាជិកគ្រួសារទាំងអស់លើក្រដាសជំរឿនសន្លឹកទី១។

**2 ប្រភេទលំនៅដ្ឋាន**

**លំនៅដ្ឋានផ្ទាល់ខ្លួន** ............ ជាម្ចាស់កម្មសិទ្ធិលើគេហដ្ឋាន។ រួមបញ្ចូលទាំងករណីមិនទាន់ចុះបញ្ជីកម្មសិទ្ធិ ឬករណីទិញតាមប្រាក់កម្ចី កម្ចីដោយមិនទាន់បានសងរួចរាល់។

**ផ្ទះជួលរបស់ស្ថាប័នរដ្ឋ/ស្ថាប័នសាធារណៈ** ...... ផ្ទះជួលរបស់ស្ថាប័នរដ្ឋ ឬស្ថាប័នសាធារណៈរបស់ខេត្ត/ស្រុក/ក្រុង/ភូមិ/ឃុំ/សង្កាត់ ឬសមាគម/ស្ថាប័នសាធារណៈអភិវឌ្ឍន៍លំនៅដ្ឋាន។
លើកលែង"លំនៅដ្ឋានរបស់ក្រុមហ៊ុន/លំនៅដ្ឋានសំរាប់បុគ្គលិកមន្ត្រីរាជការ"គឺមិនរាប់បញ្ចូលទេ។

**លំនៅដ្ឋានរបស់ក្រុមហ៊ុន/បុគ្គលិកមន្ត្រីរាជការ** ...... ករណីដែលកំពុងរស់នៅលើផ្ទះជួលរបស់ក្រុមហ៊ុន/ស្ថាប័នរដ្ឋ ឬលំនៅដ្ឋានដែលជាកម្មសិទ្ធិរបស់និយោជក។

**ផ្ទះជួលមួយចំណែក** .....................ករណីដែលជួលផ្ទះមួយចំណែករបស់គ្រួសារផ្សេងទៀតកំពុងរស់នៅ។

ប៉ុន្តែប្រសិនបើកន្លែងស្នាក់នៅមួយចំណែកដែលជួលនោះឋិតក្នុងករណីលេខ①និង②ខាងក្រោម នឹងត្រូវចាត់ទុកជា"ផ្ទះជួលរបស់ឯកជន"។

**ផ្ទះជួលរបស់ក្រុមហ៊ុនសំរាប់បុគ្គលិកនៅលីវ ឬបុគ្គលិកទូទៅ ......** គឺជាអាគារជួលឬអាគារកម្មសិទ្ធិរបស់ក្រុមហ៊ុន/ស្ថាប័នរដ្ឋ/អង្គការសំរាប់ផ្តល់អោយបុគ្គលិកនៅលីវ/បុគ្គលិកទូទៅស្នាក់នៅ។
ប៉ុន្តែប្រសិនបើកន្លែងស្នាក់នៅនោះឋិតក្នុងករណីលេខ①និង②ខាងក្រោម នឹងត្រូវចាត់ទុកជានេះហៅថា"លំនៅដ្ឋានរបស់ក្រុមហ៊ុន/លំនៅដ្ឋានបុគ្គលិកមន្ត្រីរាជការ"។

① ត្រូវបានកាត់ផ្តាច់ទាំងស្រុងជាមួយនឹងលំនៅដ្ឋានគ្រួសារដទៃ
② មានច្រកចេញចូលផ្ទាល់របស់គ្រួសារអ្នក និងមានកន្លែងចម្អិនអាហារ(ផ្ទះបាយ) បន្ទប់ទឹក
(ទោះបីជាប្រើប្រាស់រួមជាមួយគ្រួសារផ្សេងទៀតក៏ដោយ ក្នុងករណីដែលអាចប្រើប្រាស់បានគ្រប់ពេលដោយមិនចាំបាច់ឆ្លងកាត់គ្រួសារនោះ គឺត្រូវបានចាត់ទុកក្នុងករណីខាងលើនេះ។)

**អំពីសមាជិកទាំងអស់ក្នុងគ្រួសារ**

**3 ឈ្មោះនិងភេទ**

- ចំពោះទារកដែលទើបនឹងកើតត្រឹមព្រឹកម៉ោង0 ថ្ងៃទី១ ខែតុលា ឆ្នាំ២០២០ ហើយមិនទាន់បានដាក់ឈ្មោះ សូមសរសេរថា "ឈ្មោះពុំទាន់បានដាក់" នៅក្នុងកាឡេន (ឈ្មោះ) ហើយជ្រើសរើសយក ភេទ របស់ទារក។

ចំពោះ**អ្នករស់នៅជាមួយសព្វថ្ងៃ** គឺសំដៅទៅលើអ្នកដែលរស់នៅក្នុងគ្រួសាររបស់អ្នករហូតដល់ថ្ងៃទី១ ខែតុលា នេះ ទោះបីជាមិនទាន់បានចុះឈ្មោះក្នុងបញ្ជីជនបរទេសក៏ដោយ។
- ◆ អ្នកដែលបានរស់នៅលើសពី៣ខែឡើងទៅ
- ◆ ការរស់នៅមិនទាន់បានគ្រប់៣ខែ ប៉ុន្តែអាចនឹងរស់នៅលើសពី៣ខែឡើងទៅ

- ● ទោះបីមិនមែនជាសមាជិកគ្រួសាររបស់អ្នកក៏ដោយ ក្នុងករណីដែលបានរស់នៅជាមួយគ្រួសារអ្នកចាប់ពី៣ខែឡើងទៅ ឬគ្រោងនឹងរស់នៅជាមួយគ្រួសាររបស់អ្នកចាប់ពី៣ខែឡើង សូមបំពេញព័ត៌មានអំពីបុគ្គលរូបនោះផងដែរ។
- ● ចំពោះបុគ្គលដូចខាងក្រោម យើងនឹងធ្វើជំរឿនទៅតាមកន្លែងដែលបានបង្ហាញ។
  - ➢ នៅក្នុងសមាជិកគ្រួសារបើមានករណីដូចបុគ្គលខាងក្រោមនេះ សូមប្រុងប្រយ័ត្នក្នុងការបំពេញចំលើយ។

○ ចំពោះអ្នកមិននៅផ្ទះមួយរយៈដោយសារចេញទៅទេសចរណ៍ ចុះធ្វើបេសកកម្ម ចេញធ្វើការនៅខាងក្រៅជាដើម។

...... ចំពោះអ្នកដែលមិននៅផ្ទះក្រោមរយៈពេល៣ខែ នឹងត្រូវធ្វើជំរឿននៅផ្ទះកំពុងស្នាក់នៅ។

......ចំពោះអ្នកដែលមិននៅផ្ទះចាប់ពីរយៈពេល៣ខែឡើងទៅ នឹងត្រូវធ្វើជំរឿននៅកន្លែងដែលបុគ្គលនោះទៅ ទេសចរណ៍ ធ្វើបេសកកម្ម និងកន្លែងធ្វើការតែម្តង។

○ ចំពោះសិស្ស-និស្សិតដែលស្នាក់នៅតាមកន្លែកស្នាក់នៅរបស់សាលា/ផ្ទះជួលផ្សេងៗ។

...... យើងនឹងធ្វើជំរឿននៅតាមកន្លែងស្នាក់នៅរបស់សាលា/ផ្ទះជួលទាំងនោះ។

○ ចំពោះអ្នកដែលសំរាកនៅមន្ទីរពេទ្យ មន្ទីរថែរក្សាសុខភាព

......ចំពោះអ្នកដែលបានចូលសំរាកក្នុងមន្ទីរពេទ្យក្រោមរយៈពេល៣ខែ យើងនឹងធ្វើជំរឿននៅគេហដ្ឋានស្នាក់នៅ នាពេលបច្ចុប្បន្ន។

......ចំពោះអ្នកដែលសំរាកព្យាបាលនៅមន្ទីរពេទ្យចាប់ពីរយៈពេល៣ខែឡើងទៅ យើងនឹងធ្វើជំរឿន

នៅមន្ទីរពេទ្យកំពុងស្នាក់នៅ។

○ ចំពោះអ្នកដែលធ្វើការហើយស្នាក់នៅលើនាវា ...... យើងនឹងធ្វើជំរឿននៅគេហដ្ឋានស្នាក់នៅនាពេលបច្ចុប្បន្ន។

○ ចំពោះអ្នកជាប់បទល្មើសដែលរស់នៅក្នុងពន្ធនាគារ ឬត្រូវបានបញ្ជូនចូលមន្ទីរឃុំឃាំង

○ ចំពោះអ្នកដែលត្រូវបានបញ្ជូនចូលមន្ទីរណែនាំយុវជននិងមន្ទីរទទួលណែនាំស្ត្រី

...... យើងនឹងទៅធ្វើជំរឿននៅកន្លែងទាំងនោះផ្ទាល់។

○ ចំពោះអ្នកដែលមិនទាន់មានលំនៅដ្ឋានពិតប្រាកដឬកន្លែងដែលគ្រោងស្នាក់នៅចាប់ពីរយៈពេល៣ខែឡើងទៅ

......យើងនឹងធ្វើជំរឿននៅកន្លែងកំពុងនៅនាពេលបច្ចុប្បន្ន។

○ ចំពោះអ្នកដែលមានទីលំនៅពីរកន្លែង

......យើងនឹងធ្វើជំរឿននៅកន្លែងដែលបុគ្គលនោះឧស្សាហ៍មកគេង និងស្នាក់នៅជាញឹកញាប់។

## 4 ទំនាក់ទំនងជាមួយមេគ្រួសារ

ក្នុងសមាជិកគ្រួសារគឺមានម្នាក់ជា"មេគ្រួសារ ឬ តំណាងគ្រួសារ"។

សមាជិកគ្រួសារផ្សេងទៀត សូមគូសបំពេញលើទំនាក់ទំនងជាមួយនឹង"មេគ្រួសារ ឬ តំណាងគ្រួសារ" ដោយឈរលើជំហ" មេគ្រួសារ ឬ តំណាងគ្រួសារមើលមកលើទំនាក់ទំនងរបស់ខ្លួន"។

**ញាតិសន្តាន ផ្សេងទៀត** ...... ជីដូនជីតា, ចៅទួត, ពូ/មីង, ក្មួយប្រុស/ក្មួយស្រី, បងប្អូនជីដូនមួយ ឬកូនចៅរបស់សាច់ញាតិផ្សេងៗ (រាប់បញ្ចូលទាំងគូរស្រករផងដែរ)។

**ផ្សេងៗ** ..................ករណីដូចជាទទួលចិញ្ចឹមកូនរបស់មិត្តភ័ក្ត្រ ឬអ្នករស់នៅជាមួយក្រៅពីសាច់ញាតិ (ក្រៅពីអ្នកមករស់នៅដើម្បីធ្វើការ)។

## 7 សញ្ជាតិ

ចំពោះអ្នកដែលមានសញ្ជាតិចាប់ពី២ឡើងទៅ អ្នកមានសញ្ជាតិជប៉ុនគឺត្រូវចុះថា"ជប៉ុន"។

ចំពោះអ្នកគ្មានសញ្ជាតិជប៉ុន សូមសរសេរឈ្មោះប្រទេសអ្នកនៅក្នុងតារាង [(ឈ្មោះប្រទេស) ] នេះ។

## 8 រយៈពេលដែលបានរស់នៅទីកន្លែងបច្ចុប្បន្ន

បន្ទាប់ពីចាប់ផ្តើមរស់នៅកន្លែងស្នាក់នៅបច្ចុប្បន្ន ក្នុងករណីចាកចេញជាបណ្តោះអាសន្នចាប់ពី៣ខែឡើងទៅ ដោយសារការប្តូរការងារ ការទៅរស់នៅម្នាក់ឯងដើម្បីធ្វើការ ទេសចរណ៍ ចុះបេសកកម្ម ឬ ស្វែងរកប្រាក់ចំណូលជាដើម សូមគូសលើចំលើយដែលមានរយៈពេលគិតចាប់ពីអ្នកបានវិលត្រឡប់មកស្នាក់នៅវិញ។

## 9 កាលពី៥ឆ្នាំមុន (ថ្ងៃទី១ ខែតុលា ឆ្នាំ២០១៥) តើអ្នកបានរស់នៅទីណា?

សូមសរសេរអាសយដ្ឋានដែលអ្នកបានរស់នៅជាអចិន្ត្រៃយ៍កាលពី៥ឆ្នាំមុន(ថ្ងៃទី១ ខែតុលា ឆ្នាំ២០១៥)។

➢ចំពោះទារកដែលទើបនឹងកើត ហើយស្នាក់នៅមន្ទីរពេទ្យនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២០ សូមសរសេរអាសយដ្ឋានរស់នៅក្រោយពីទារកចេញពីមន្ទីរពេទ្យ។

➢នៅទីក្រុងតូក្យូគឺមាន ២៣ សង្កាត់ដូចខាងក្រោម

Chiyoda-ku,Chuo-ku,Minato-ku,Shinjuku-ku,Bunkyo-ku,Taito-ku,Sumida-ku,Koto-ku,
Shinagawa-ku,Meguro-ku,Ota-ku,Setagaya-ku,Shibuya-ku,Nakano-ku,Suginami-ku,Toshima-ku,
Kita-ku,Arakawa-ku,Itabasi-ku,Nerima-ku,Adachi-ku,Katsusika-ku,Edogawa-ku

## ក្រដាសជំរឿន របៀបបំពេញនៅលើទំព័រទី2

**អំពីសមាជិកទាំងអស់ក្នុងគ្រួសារ**

**11 ក្នុងរយៈពេល១សប្តាហ៍ចាប់ពី ថ្ងៃទី២៤ រហូតដល់ ថ្ងៃទី៣០ ខែកញ្ញា តើអ្នកបានធ្វើការដែរឺទេ？**

ក្នុងរយៈពេលមួយសប្តាហ៍ចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី៣០ ខែកញ្ញានេះ អ្នកដែលបានធ្វើការហើយបានប្រាក់ចំណូលទោះបីជាបន្តិចបន្តួចក៏ដោយ សូមបំពេញនៅចំលើយផ្នែកខាងលើ។ ចំណែកឯអ្នកដែលមិនបានធ្វើការងារទទួលប្រាក់ចំណូលទោះបីជាបន្តិចបន្តួចក៏ដោយនោះ សូមបំពេញនៅចំលើយផ្នែកខាងក្រោម។

ចំពោះអ្នកមានសិទ្ធិស្នាក់នៅជា"ការសិក្សាជំនាញ" ហើយបិតនៅក្នុងរយៈពេលសិក្សា សូមគូសបំពេញនៅលើពាក្យថា "ទៅសាលា"។

**ធ្វើកិច្ចការផ្ទះ និង ការងារផ្សេងទៀត** ......សំដៅលើអ្នកធ្វើកិច្ចការផ្ទះជាចំបង ប៉ុន្តែក្រៅពីនោះ នៅមានធ្វើការក្រៅម៉ោងផ្សេងៗ ក៏ដូចជា ការជួយមុខរបរជំនួញក្នុងផ្ទះ ការងារបានប្រាក់ឈ្នួលជាដើម ដែលទទួលបានប្រាក់កម្រៃទោះបីជាបន្តិចបន្តួចក៏ដោយ។

**បានឈប់សំរាកពីការងារ** ......សំដៅលើ**អ្នកកំពុងធ្វើការ** ប៉ុន្តែបានឈប់សំរាកដោយសារជំងឺ ឬបិតក្នុងវិស្សមកាលការងារ ហើយបានទទួលប្រាក់ខែក្នុងកំឡុងពេលឈប់សំរាកនោះ ឬអ្នកដែលអាចទទួលប្រាក់ក្នុងពេលឈប់សំរាកដើម្បីថែទាំសុខភាព ឬប្រាក់មូលដ្ឋានក្នុងពេលឈប់សំរាកដើម្បីថែទាំកូនដែលបានផ្អែកទៅតាមច្បាប់ធានាលើពលកម្ម។

**អ្នកកំពុងប្រកបរបរអាជីវកម្ម** ប៉ុន្តែឈប់សំរាកដោយសារជំងឺ ឬបិតក្នុងវិស្សមកាលការងារមិនទាន់បានគ្រប់៣០ថ្ងៃ។

**បានស្វែងរកការងារធ្វើ** ...... គ្មានការងារធ្វើហើយបានព្យាយាមស្វែងរកការងារតាមរយៈការដាក់ពាក្យស្វែងរកការងារធ្វើនៅHello-Work (កន្លែងណែនាំការងារជាសាធារណៈ) ឬតាមរយៈការផ្សាយព័ត៌មានជ្រើសរើសបុគ្គលិកនៅក្នុងកាសែតឬពឹងពាក់នរណាម្នាក់អោយជួយណែនាំការងារអោយ។
ប៉ុន្តែ លើកលែងតែក្នុងករណីដែលរកឃើញការងារធ្វើ ហើយការងារនោះអាចចាប់ផ្តើមធ្វើបានភ្លាមតែប៉ុណ្ណោះ។

**ទៅសាលា** .........ករណីទៅរៀនភាសាជប៉ុន និង ទៅរៀនវិជ្ជាធ្វើម្ហូបក្នុងមួយសប្តាហ៍១ដង ឬ ២ដង គឺមិនគិតបញ្ចូលទេ។

➤ករណីកំពុងទៅសាលាមតេយ្យ មន្ទីរថែទាំកុមារ ឬមណ្ឌលថែទាំកុមារដែលត្រូវបានទទួលស្គាល់ពីរដ្ឋ គឺចាត់ទុកថានៅក្នុងចំណុច "ផ្សេងៗ"។

**ចំពោះអ្នកដែលកំពុងមានការងារធ្វើ/អ្នកកំពុងសិក្សា**

**12 កន្លែងធ្វើការ ឬ កន្លែងកំពុងសិក្សា**

- អ្នកកំពុងមានការងារធ្វើផង និងកំពុងសិក្សាផងនោះ សូមគូសបំពេញលើកន្លែងធ្វើការ។
  - ➤ ចំពោះអ្នករស់នៅក្នុងទីក្រុងតូក្យូ សូមមើលការពន្យល់នៅទំព័រទី4សំរាប់ទុកជាឯកសារជំនួយ "9 កាលពី៥ឆ្នាំមុន (ថ្ងៃទី១ ខែតុលា ឆ្នាំ២០១៥) តើអ្នកបានរស់នៅទីណា？"។
- ចំពោះបុគ្គលដូចខាងក្រោមនេះ កន្លែងធ្វើការគឺត្រូវបានកំណត់តាមការបង្ហាញនិមួយៗ។
  - ○ អ្នកធ្វើការនៅកសិដ្ឋានផ្ទាល់ខ្លួន/តំបន់ព្រៃភ្នំ/ទូកនេសាទ ......លំនៅដ្ឋានផ្ទាល់ខ្លួន

○ អ្នកបើកអាជីវកម្មផ្ទាល់ខ្លួនដូចជាជាងឈើ និងអ្នកជំនួញផ្សេងៗ ...... លំនៅដ្ឋានផ្ទាល់ខ្លួន

○ អ្នកដែលធ្វើការអោយគេហើយធ្វើការនៅខាងក្រៅ ......នៅក្រុង/ភូមិ/ឃុំ/សង្កាត់ដែលមានកន្លែងអាជីវកម្មនៃកន្លែងធ្វើការរបស់ខ្លួន (បុគ្គលិកធ្វើការនៅក្រៅក្រុមហ៊ុន ដូចជាអ្នកបើកឡានជាដើម)

○ អ្នកធ្វើការនៅលើនាវា ...... នៅក្រុង/ភូមិ/ឃុំ/សង្កាត់ដែលមានកំពង់ផែសំរាប់នាវានោះចុះចតជាប្រចាំ

**13 មធ្យោបាយធ្វើដំណើរទៅកាន់កន្លែងធ្វើការ ឬកន្លែងសិក្សា**

● ក្នុងករណីមធ្យោបាយធ្វើដំណើរមានការខុសគ្នាទៅតាមថ្ងៃនិមួយៗ សូមគូសបំពេញលើមធ្យោបាយធ្វើដំណើរដែលអ្នកប្រើជាចំបង។

● ក្នុងករណីមធ្យោបាយធ្វើដំណើរ “ពេលទៅ” និង “ពេលត្រឡប់មកវិញ” ខុសគ្នា សូមគូសបំពេញទាក់ទងនឹង “ពេលទៅ”។

**អំពីអ្នកកំពុងធ្វើការ**

**14 អ្នកធ្វើការអោយគេ ឬធ្វើអាជីវកម្មផ្ទាល់ខ្លួន**

**អ្នកធ្វើការអោយគេ** ...... គឺសំដៅទៅលើអ្នកដែលធ្វើការអោយគេដូចជានៅតាមក្រុមហ៊ុន/អង្គការ/ស្ថាប័នរដ្ឋនិងហាងទំនិញឯកជនជាដើម។

**បុគ្គលិកបញ្ជូនពីក្រុមហ៊ុន**......នៅចំណុចបុគ្គលិកបញ្ជូនពីក្រុមហ៊ុន សម្រាប់”អ្នកធ្វើការក្រៅម៉ោង” ក៏ត្រូវបានរាប់បញ្ចូលជា”បុគ្គលិកបញ្ជូនពីក្រុមហ៊ុន”ផងដែរ។

**បុគ្គលិកថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន**......បុគ្គលិកថ្នាក់ខ្ពស់ដែលមានតួនាទីដូចជាប្រធានក្រុមហ៊ុន/នាយកចាត់ការទូទៅ/នាយកសវនកម្ម/អ្នកទទួលបន្ទុកផ្នែកនាយកចាត់ចែង និងត្រួតពិនិត្យនៅនីតិបុគ្គលសាធារណៈ/អង្គការ ឬ នីតិបុគ្គលឯកជនជាដើម។

➢ ប្រធានផ្នែក ប្រធានក្រុម ក៏ដូចជាបុគ្គលិកថ្នាក់ខ្ពស់ទទួលបន្ទុកផ្នែកគ្រប់គ្រង និងផ្នែកប្រតិបត្តិ ប្រសិនបើមិនមែនបិតក្នុងតួនាទីជានាយកចាត់ការទូទៅ ឬនាយកចាត់ចែងទេនោះ គឺត្រូវចាត់ទុកជា”អ្នកធ្វើការអោយគេ”។

**ម្ចាស់អាជីវកម្ម** ............... ប្រសិនបើមានជួលបុគ្គលិកអោយធ្វើការ សូមដាក់ថា”មានបុគ្គលិកជួយធ្វើការ”។
ប្រសិនបើមិនមានជួលបុគ្គលិកអោយធ្វើការទេ សូមដាក់ថា”គ្មានបុគ្គលិកជួយធ្វើការ”។

➢អ្នកគ្រប់គ្រងហាងទំនិញ ដែលហាងនោះមានលក្ខណៈជាសាខារបស់ក្រុមហ៊ុន (ក្រុមហ៊ុនដែលមានភាគហ៊ុន (រួមទាំងក្រុមហ៊ុនអាហារ៉ែណាំចៃហារ៉ែណ) មានភាគហ៊ុនរួមគ្នា/មានឈ្មោះរួមគ្នា/មានក្រុមហ៊ុនសាជីវកម្មរួមគ្នា) នឹងត្រូវចាត់ទុកជា”បុគ្គលិកថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន”។

**អ្នកប្រកបការងារជាលក្ខណៈគ្រួសារ** ......... គ្រួសារដែលជួយធ្វើការងារក្នុងហាង និងការងារកសិកម្មនៅកសិដ្ឋាន ឬ ហាងទំនិញឯកជនផ្សេងៗ។

**ការងារទទួលធ្វើនៅផ្ទះ** ......... គឺជាការងារដែលមិនចាំបាច់មានឧបករណ៍ទ្រង់ទ្រាយធំ ហើយត្រូវបានគេផ្តល់សម្ភារៈអោយអាចយកមកធ្វើនៅផ្ទះម្នាក់ឯងបាន។

**15 ឈ្មោះកន្លែងធ្វើការ**

- សូមសរសេរឈ្មោះកន្លែងការងាររបស់ខ្លួនកំពុងធ្វើ (ក្រុមហ៊ុន សាខាក្រុមហ៊ុន កន្លែងធ្វើអាជីវកម្ម រោងចក្រ ហាងទំនិញ ជាដើម)។
  - ○ អ្នកដែលធ្វើការនៅសាខា/កន្លែងធ្វើអាជីវកម្មផ្សេងៗ  មិនត្រឹមតែត្រូវសរសេរឈ្មោះក្រុមហ៊ុនប៉ុណ្ណោះទេ គឺចាំបាច់ត្រូវសរសេរឈ្មោះសាខា និងទីកន្លែងធ្វើអាជីវកម្មដែលខ្លួនកំពុងធ្វើការផងដែរ។
  - ○ អ្នកដែលកំពុងធ្វើការនៅកន្លែងការងារចាប់ពី២ឡើង សូមសរសេរឈ្មោះការងារដែលធ្វើរយៈពេលវែងជាងគេ។
  - ○ បុគ្គលិកបញ្ជូនពីក្រុមហ៊ុន ត្រូវសរសេរឈ្មោះកន្លែងអាជីវកម្មដែលត្រូវបានបញ្ជូន។

**15 ខ្លឹមសារការងារនៅកន្លែងធ្វើការ**

- សូមសរសេរខ្លឹមសារការងារសំខាន់ដែលកំពុងធ្វើនៅកន្លែងការងារ។
- សូមសរសេរអោយងាយយល់នូវការបែងចែកដូចជា: ផលិតផល/ទំនិញសំខាន់ ប្រភេទសេវាកម្ម ការផលិត ឬការជួសជុល លក់បោះដុំ ឬលក់រាយ។
  - ○ ក្នុងករណីកំពុងធ្វើការងារផ្សេងគ្នានៅកន្លែងការងារនោះ លើសពី២ប្រភេទឡើង សូមសរសេរខ្លឹមសារការងារសំខាន់តែមួយបានហើយ។
  - ○ ក្នុងករណីផលិតផលត្រូវបានលក់រាយជូនអតិថិជនទូទៅនៅទីកន្លែងផលិតផ្ទាល់នោះ ត្រូវសរសេរថា “ផលិតនិងលក់រាយ .........”។
  - ○ បុគ្គលិកបញ្ជូនពីក្រុមហ៊ុន សូមបំពេញខ្លឹមសារការងារនៅក្រុមហ៊ុនអាជីវកម្មដែលត្រូវបានបញ្ជូនអោយទៅធ្វើការ។

**16 អត្ថន័យនៃខ្លឹមសារការងារ**

- ○ សូមសរសេរខ្លឹមសារការងារសំខាន់ដែលសាមីខ្លួនកំពុងធ្វើជាក់ស្តែងនៅកន្លែងការងារនោះ។
- ○ ក្នុងករណីខ្លឹមសារការងារមានឈ្មោះច្បាស់លាស់ដូចជា “អ្នកវិភាគប័ណ្ណភាគហ៊ុន” “មេធាវីផ្នែកអន្តរជាតិ” “អ្នករចនា” ជាដើម សូមសរសេរឈ្មោះការងារនោះតែម្តង។
- ○ សម្រាប់អ្នកដែលកំពុងធ្វើការងារផ្សេងគ្នាលើសពី២ប្រភេទឡើង សូមសរសេរខ្លឹមសារការងារណាមួយដែលមានរយៈពេលម៉ោងការងារច្រើនជាងគេ។
  - ➤ក្រៅពីកំពុងធ្វើការងារជាអ្នកគ្រប់គ្រង/អ្នកធ្វើអាជីវកម្ម ហើយប្រតិបត្តិការងារទាក់ទងនឹងជំនាញ/បច្ចេកទេសដូចជាមេចុងភៅ ការផលិត/ការជួសជុល ជាដើម សូមបំពេញក្នុងការងារជំនាញ/បច្ចេកទេស។

    ឧទាហរណ៍: ការគ្រប់គ្រងការិយាល័យច្បាប់ និងមេធាវី ...............មេធាវី

    អ្នកគ្រប់គ្រងនៅភោជនីយដ្ឋាន និងមេចុងភៅ ......... មេចុងភៅ
- ○ បុគ្គលិកបញ្ជូនពីក្រុមហ៊ុន សូមបំពេញខ្លឹមសារការងារជាក់ស្តែងដែលខ្លួនធ្វើនៅកន្លែងដែលបានបញ្ជូន។

**ឧទាហរណ៍របស់; 15, 16**

〔ឧទាហរណ៍ 1〕ការងារឧស្សាហកម្មផលិត

| | | |
|---|---|---|
| ជួរទី15 | ឈ្មោះក្រុមហ៊ុន | ក្រុមហ៊ុនយានយន្ត AOSORA រោងចក្រទី១ |
| | ខ្លឹមសារអាជីវកម្ម | ការផលិតប្រអប់លេខម៉ាស៊ីន |
| ជួរទី16 | ខ្លឹមសារការងារ | ការតំឡើងប្រអប់លេខម៉ាស៊ីន |

〔ឧទាហរណ៍ 2〕ផ្នែកសេវាកម្ម

| | | |
|---|---|---|
| ជួរទី15 | ឈ្មោះក្រុមហ៊ុន | (ក្រុមហ៊ុន)Total Care Center |
| | ខ្លឹមសារអាជីវកម្ម | ចុះសួរសុខទុក្ខចាស់ជរាដល់គេហដ្ឋានផ្ទាល់ ជួយសំអាតកាយ និង ជួយរៀបចំចំណីអាហារ ជាដើម |
| ជួរទី16 | ខ្លឹមសារការងារ | អ្នកជួយទំនុកបំរុងតាមគេហដ្ឋាន |

〔ឧទាហរណ៍ 3〕ផ្នែកលក់ទំនិញបោះដុំ

| | | |
|---|---|---|
| ជួរទី15 | ឈ្មោះក្រុមហ៊ុន | ក្រុមហ៊ុនពាណិជ្ជកម្ម RIKA |
| | ខ្លឹមសារអាជីវកម្ម | លក់បោះដុំស្រាបរទេស |
| ជួរទី16 | ខ្លឹមសារការងារ | ការនាំទំនិញចូលឃ្លាំង |

ប្រសិនបើអ្នកមានចម្ងល់ទាក់ទងនឹងការជំរឿននេះ សូមទាក់ទងមកកាន់អាសយដ្ឋានខាងក្រោម។

| |
|---|
| អាសយដ្ឋានទំនាក់ទំនងរបស់ក្រុង/ភូមិ/ឃុំ/សង្កាត់ |